# សេចក្តីផ្តើម

គោលការណ៍ណែនាំស្តីពី ការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ក្នុងគោលបំណងណែនាំដល់ម្ចាស់សំណើ និងម្ចាស់គម្រោងឱ្យអនុវត្តនិងបំពេញបែបបទតាមនីតិវិធីទាំង៤ ដំណាក់កាលដូចមានចែងក្នុងឧបសម្ព័ន្ធ១។

គោលការណ៍ណែនាំនេះ មានវិសាលភាពអនុវត្តលើគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ដោយប្រើប្រាស់លក្ខណៈវិនិច្ឆ័យ ដូចមានចែងក្នុងឧបសម្ព័ន្ធ២។

គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ អាចធ្វើឡើងក្នុងទម្រង់ជា៖

១. គម្រោងវិស័យឯកជន ឬ
២. គម្រោងសហការរួមគ្នារវាងវិស័យឯកជនជាមួយនឹងសហគមន៍មូលដ្ឋាន។

គោលការណ៍ណែនាំនេះត្រូវបានរៀបចំឡើង ដោយទទួលបាននូវការចូលរួមផ្តល់គំនិតយោបល់ពីអ្នកពាក់ព័ន្ធ តាមរយៈកិច្ចប្រជុំបច្ចេកទេសជាបន្តបន្ទាប់ និងសិក្ខាសាលាពិគ្រោះយោបល់នៅថ្នាក់ជាតិ។

អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាសេនាធិការរបស់ក្រសួងបរិស្ថានដែលមានភារកិច្ចសម្របសម្រួល និងអនុវត្តនីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ។

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងបរិស្ថាន

លេខៈ ៤៩៤ ប្រក ....ប.ស្ក

# ប្រកាស

## ស្តីពី

## ការដាក់ឱ្យអនុវត្តនូវគោលការណ៍ណែនាំ ក្នុងការអនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចដែល មានទំហំផ្ទៃដីក្រោម ១០(ដប់) ហិកតា ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

## រដ្ឋមន្ត្រីក្រសួងបរិស្ថាន

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំង និងកែសម្រួលសមាសភាពរាជរដ្ឋាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/២១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងបរិស្ថាន
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៨០១/១៤ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ភូមិបាល
- បានឃើញព្រះរាជក្រឹត្យចុះថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ១៩៩៣ស្តីពីការបង្កើត និងការកំណត់តំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២៩៦/៣៦ ចុះថ្ងៃទី២៤ ខែធ្នូ ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីកិច្ចការពារបរិស្ថាន និងការគ្រប់គ្រងធនធានធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០២០៨/០០៧ ចុះថ្ងៃទី១៥ ខែកុម្ភៈ ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីតំបន់ការពារធម្មជាតិ
- បានឃើញព្រះរាជក្រមលេខ នស/រកម/១១២០/០៣០ ចុះថ្ងៃទី០៦ ខែតុលា ឆ្នាំ២០២០ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រង ការប្រើប្រាស់ និងការចាត់ចែងលើទ្រព្យសម្បត្តិរដ្ឋ

១/២

- បានឃើញអនុក្រឹត្យលេខ ៧២ អនក្រ.បក ចុះថ្ងៃទី១១ ខែសីហា ឆ្នាំ១៩៩៩ ស្តីពីកិច្ចដំណើរការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន
- បានឃើញអនុក្រឹត្យលេខ ២៣៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែវិច្ឆិកា ឆ្នាំ២០២១ របស់រាជរដ្ឋាភិបាល ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងបរិស្ថាន
- បានឃើញប្រកាសលេខ ២១ ប្រក.ប.ស្ថ ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍
- បានឃើញប្រកាសលេខ ២២៧ ប្រក.បស្ថ ចុះថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២១ ស្តីពីនីតិវិធី និងការអនុវត្តគោលការណ៍ណែនាំសម្រាប់តារាងផ្ទៀងផ្ទាត់ក្នុងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្ខេបដំបូងលើគម្រោងអភិវឌ្ឍន៍តំបន់ទេសចរណ៍
- បានឃើញលិខិតលេខ ៩៥១ សជណ.កស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- យោងតាមការចាំបាច់របស់ក្រសួងបរិស្ថាន

## សម្រេច

**ប្រការ ១.-**

ប្រកាសនេះមានគោលបំណងដាក់ឱ្យអនុវត្តគោលការណ៍ណែនាំ សម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ។

**ប្រការ ២.-**

នាយកខុទ្ទកាល័យ គ្រប់អគ្គនាយកនៃអគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន នាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានវាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងបរិស្ថាន ត្រូវអនុវត្តប្រកាសនេះ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ ខែ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៦
ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែ ឆ្នាំ២០២២

**រដ្ឋមន្ត្រី**

**សាយ សំអាល់**

**កន្លែងទទួល៖**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- រដ្ឋបាលខេត្តពាក់ព័ន្ធ
- ដូចប្រការ២
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

២/២

## ឧបសម្ព័ន្ធ១

## នីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា ស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

| សកម្មភាព | អ្នកអនុវត្ត |
|---|---|
| **ដំណាក់កាលទី១៖ ដំណើរការស្នើសុំ** | |
| **១.១.ម្ចាស់សំណើ (នីតិបុគ្គល ឬ រូបវន្តបុគ្គល) ត្រូវដាក់ពាក្យស្នើសុំអភិវឌ្ឍន៍គម្រោងទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ក្រោមទម្រង់ជាគម្រោងវិស័យឯកជន ឬគម្រោងសហការរួមគ្នា រវាងវិស័យឯកជនជាមួយនឹងសហគមន៍មូលដ្ឋាននៅច្រកចេញ-ចូលតែមួយនៃទីស្តីការក្រសួងបរិស្ថាន ដោយត្រូវមានឯកសារចាំបាច់ដូចខាងក្រោម៖**<br>- ពាក្យស្នើសុំដែលមានបញ្ជាក់ពីចំណុចនិយាមកា និងទីតាំង<br>- ឯកសារទស្សនទាននៃគម្រោង<br>- ឯកសារចុះបញ្ជីក្រុមហ៊ុន ឬ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ចំពោះរូបវន្តបុគ្គល)<br>*(ករណីម្ចាស់សំណើមិនបានផ្តល់ឯកសារគ្រប់គ្រាន់តាមចំណុចខាងលើ សំណើសុំនេះនឹងមិនត្រូវពិចារណាក្នុងការបន្តនីតិវិធីឡើយ)* | - ម្ចាស់សំណើ |
| **ដំណាក់កាលទី២៖ ដំណើរការវាយតម្លៃ (រយៈពេល ៤៥ ថ្ងៃនៃថ្ងៃធ្វើការ)** | |
| **២.១.ការពិនិត្យ សិក្សាឯកសារស្នើសុំ៖**<br>- ពិនិត្យឯកសារចុះបញ្ជីក្រុមហ៊ុន ឯកសារទស្សនទាន និងផ្ទៀងផ្ទាត់និយាមកាក្នុងសំណើ ជៀសវាងមានការជាន់លើទីតាំងដែលទទួលបានសិទ្ធិអភិវឌ្ឍន៍រួច ឬ ទីតាំងស្ថិតនៅក្រៅតំបន់ការពារធម្មជាតិ ឬ នៅក្រៅរបៀងអភិរក្សជីវៈចម្រុះ។<br>- រៀបចំកំណត់បង្ហាញ និងសុំគោលការណ៍ថ្នាក់ដឹកនាំ។<br>- ម្ចាស់សំណើធ្វើបទបង្ហាញអំពីទស្សនទាននៃគម្រោង (ករណីមិនមានការជាន់លើទីតាំង និងទីតាំងស្ថិតនៅក្នុងតំបន់ការពារធម្មជាតិ)។ | - ក្រុមការងារដឹកនាំដោយថ្នាក់ដឹកនាំក្រសួងទទួលបន្ទុកខេត្តគោលដៅ និងនាយកដ្ឋានពាក់ព័ន្ធ<br><br>- ម្ចាស់សំណើ |
| **២.២.ការចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង៖**<br>- ចុះពិនិត្យទីតាំងស្នើសុំ ដោយប្រើប្រាស់តារាងលក្ខណៈវិនិច្ឆ័យដូចមានចែងក្នុងឧបសម្ព័ន្ធ២សម្រាប់វាយតម្លៃនៅទីវាលជាក់ស្តែង។<br>- រៀបចំកិច្ចប្រជុំបូកសរុបលទ្ធផល និងកំណត់ហេតុ។ | - ក្រុមការងារដឹកនាំដោយថ្នាក់ដឹកនាំក្រសួងទទួលបន្ទុកខេត្តគោលដៅដោយមានការចូលរួមពីតំណាង |

| សកម្មភាព | អ្នកអនុវត្ត |
|---|---|
| | រដ្ឋបាលថ្នាក់ក្រោមជាតិនិង អាជ្ញាធរពាក់ព័ន្ធ និងម្ចាស់សំណើ |
| **២.៣.ការសម្រេចរបស់ក្រសួងបរិស្ថានៈ**<br>- រៀបចំរបាយការណ៍ ដោយភ្ជាប់នូវកំណត់ហេតុនៃការចុះពិនិត្យទីតាំងជាក់ស្តែង ផែនទី និយាមកាច្បាស់លាស់ ដាក់ជូនឯកឧត្តមរដ្ឋមន្ត្រី ពិនិត្យ និងសម្រេច។<br>- រៀបចំសេចក្តីជូនដំណឹងជាគោលការណ៍ (សជណ) បន្ទាប់ពីការសម្រេចរបស់ឯកឧត្តមរដ្ឋមន្ត្រី។ | - នាយកដ្ឋានទេសចរណ៍ធម្មជាតិ |
| **ដំណាក់កាលទី៣៖ ដំណើរការបំពេញនីតិវិធី (រយៈពេល ១៨០ថ្ងៃ បន្ទាប់ពីថ្ងៃទទួលបាន សជណ អនុញ្ញាត)** | |
| **៣.១.ការបោះបង្គោលព្រំទីតាំងគម្រោងៈ**<br>- ម្ចាស់គម្រោងដាក់សំណើមកក្រសួងបរិស្ថាន ដើម្បីស្នើសុំធ្វើការកំណត់ទីតាំង និងបោះបង្គោលព្រំដី បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាគោលការណ៍ពីក្រសួងបរិស្ថាន(សជណ)។ | - ម្ចាស់គម្រោង |
| - ក្រសួងបរិស្ថានចេញសេចក្តីជូនដំណឹង និងអនុញ្ញាតឱ្យមន្ទីរបរិស្ថានខេត្តគោលដៅសម្របសម្រួលជាមួយរដ្ឋបាលខេត្ត អង្គភាពពាក់ព័ន្ធ និងម្ចាស់គម្រោង ដើម្បីរៀបចំក្រុមការងារចុះសិក្សា កំណត់ទីតាំងបោះបង្គោលព្រំដី។ | - មន្ទីរបរិស្ថានខេត្តគោលដៅ សម្របសម្រួលជាមួយ រដ្ឋបាលខេត្ត និងអង្គភាព ពាក់ព័ន្ធ និងម្ចាស់គម្រោង |
| **៣.២.ការចុះបញ្ជីក្រុមហ៊ុន និងការចុះកិច្ចសន្យាប្រើប្រាស់ទីតាំងៈ**<br>- ម្ចាស់គម្រោងផ្តល់ឯកសារចុះបញ្ជីក្រុមហ៊ុន (ករណីរូបវន្តបុគ្គល) បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាគោលការណ៍ពីក្រសួងបរិស្ថាន (សជណ)។ | - ម្ចាស់គម្រោង |
| - ម្ចាស់គម្រោងដាក់សំណើមកក្រសួងបរិស្ថាន ដើម្បីស្នើសុំចុះកិច្ចសន្យាប្រើប្រាស់ទីតាំង បន្ទាប់ពីទទួលបានលិខិតអនុញ្ញាតជាគោលការណ៍ពីក្រសួងបរិស្ថាន(សជណ)។ | - ម្ចាស់គម្រោង |
| - រៀបចំកិច្ចសន្យាប្រើប្រាស់ទីតាំង បន្ទាប់ពីទទួលបានលិខិតស្នើសុំ។ | - នាយកដ្ឋានទេសចរណ៍ធម្មជាតិ |
| - ចុះកិច្ចសន្យាប្រើប្រាស់ទីតាំង។ | - អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន និងម្ចាស់គម្រោង |
| **៣.៣.ការរៀបចំប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ៈ**<br>- ម្ចាស់គម្រោងដាក់សេចក្តីព្រាងប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍មកក្រសួងបរិស្ថាន ដើម្បីពិនិត្យ និងសម្រេច បន្ទាប់ពីចុះកិច្ចសន្យាប្រើប្រាស់ទីតាំង។ | - ម្ចាស់គម្រោង |

| សកម្មភាព | អ្នកអនុវត្ត |
| --- | --- |
| - ក្រសួងបរិស្ថានរៀបចំកិច្ចប្រជុំដើម្បីពិនិត្យ និងសម្រេចសេចក្តីព្រាងប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍។ | - ក្រុមការងារដឹកនាំដោយថ្នាក់ដឹកនាំក្រសួងទទួលបន្ទុកខេត្តគោលដៅ ដោយមានការចូលរួមពីតំណាងរដ្ឋបាលថ្នាក់ក្រោមជាតិ អាជ្ញាធរពាក់ព័ន្ធ និងម្ចាស់គម្រោង |
| **៣.៤.ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម៖**<br>- ម្ចាស់គម្រោងត្រូវស្នើសុំចុះកិច្ចសន្យាការពារបរិស្ថាន ស្របតាមប្រកាសលេខ ០២១ ប្រក ប.ស្ក ចុះថ្ងៃទី០៣ ខែកុម្ភៈ ឆ្នាំ២០២០ ស្តីពីចំណាត់ថ្នាក់នៃការវាយតម្លៃហេតុប៉ះពាល់បរិស្ថានសម្រាប់គម្រោងអភិវឌ្ឍន៍ មកក្រសួងបរិស្ថានដើម្បីពិនិត្យ និងសម្រេចបន្ទាប់ពីចុះកិច្ចសន្យាប្រើប្រាស់ទីតាំង។<br>- ចុះកិច្ចសន្យាការពារបរិស្ថាន។ | - ម្ចាស់គម្រោង<br>- ក្រសួងបរិស្ថាន និងម្ចាស់គម្រោង |
| **ដំណាក់កាលទី៤៖ ដំណើរការអនុវត្តគម្រោង** | |
| **៤.១.ការអនុវត្តគម្រោងតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍៖**<br>- ម្ចាស់គម្រោងអនុវត្តសកម្មភាពនៅទីវាលស្របតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងកិច្ចសន្យាការពារបរិស្ថានដែលត្រូវបានឯកភាព។ | - ម្ចាស់គម្រោង |
| **៤.២.ការរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង៖**<br>- ម្ចាស់គម្រោងរៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោងដោយរួមបញ្ចូលទាំងបញ្ហាប្រឈម និងសំណូមពរមកក្រសួងបរិស្ថាននៅរៀងរាល់ឆមាស។ | - ម្ចាស់គម្រោង |
| **៤.៣.ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ៖**<br>- ចុះត្រួតពិនិត្យតាមដាន និងវាយតម្លៃលើវឌ្ឍនភាពនៃការអនុវត្តគម្រោងរៀងរាល់ឆមាស និងក្នុងករណីចាំបាច់។ | - ក្រុមការងារក្រសួងបរិស្ថានដោយមានការចូលរួមពីរដ្ឋបាលថ្នាក់ក្រោមជាតិ និងអាជ្ញាធរពាក់ព័ន្ធ និងម្ចាស់គម្រោង |

**សម្គាល់៖** *អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ជាសេនាធិការរបស់ក្រសួងបរិស្ថាន មានភារកិច្ចសម្របសម្រួល និងអនុវត្តនីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ។*

# ដ្យាក្រាមនៃនីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ ដែលមានទំហំផ្ទៃដីក្រោម ១០(ដប់) ហិកតាខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

## ដំណាក់កាលទី១៖ ដំណើរការស្នើសុំ

### ១.១ ម្ចាស់សំណើត្រូវមានឯកសារចាំបាច់ដូចខាងក្រោម៖

| ១ | ២ | ៣ |
|---|---|---|
| • ពាក្យស្នើសុំដែលមានបញ្ជាក់ពីចំណុចនិយាមកា និងទីតាំង | • ឯកសារទស្សនទាននៃគម្រោង | •ឯកសារចុះបញ្ជីក្រុមហ៊ុន ឬ អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ (ចំពោះរូបវន្តបុគ្គល) |

*ក្នុងករណីម្ចាស់សំណើមិនបានផ្តល់ឯកសារគ្រប់គ្រាន់តាមចំណុចខាងលើ សំណើសុំនេះនឹងមិនត្រូវបានពិចារណាក្នុងការបន្តនីតិវិធីឡើយ*

## ដំណាក់កាលទី២៖ ដំណើរការវាយតម្លៃ

*រយៈពេល២៥ថ្ងៃ នៃថ្ងៃធ្វើការ*

២.១. ការពិនិត្យសិក្សាឯកសារស្នើសុំ

↓

២.២. ការចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង

↓

២.៣. ការសម្រេចរបស់ក្រសួងបរិស្ថាន

## ដំណាក់កាលទី៣៖ ដំណើរការបំពេញនីតិវិធី

*រយៈពេល១៨០ថ្ងៃ នៃថ្ងៃធ្វើការដោយគិតចាប់ពីថ្ងៃ ទទួលបាន សេចក្តី អនុញ្ញាតពីក្រសួងបរិស្ថាន*

៣.១.ការបោះបង្គោលព្រំទីតាំងគម្រោង

៣.២.ការចុះបញ្ជីក្រុមហ៊ុន និងការចុះកិច្ចសន្យាប្រើប្រាស់ទីតាំង

៣.៣.ការរៀបចំប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍

៣.៤.ការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម

## ដំណាក់កាលទី៤៖ ដំណើរការអនុវត្តគម្រោង

៤.១.ការអនុវត្តគម្រោងតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍

៤.២.រៀបចំរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគម្រោង

៤.៣.ការត្រួតពិនិត្យតាមដាន និងវាយតម្លៃ

## ឧបសម្ព័ន្ធ២

## លក្ខណៈវិនិច្ឆ័យសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ដែលមានទំហំផ្ទៃដីក្រោម ១០ (ដប់) ហិកតា នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| *កំណត់សម្គាល់៖ លក្ខណៈវិនិច្ឆ័យទី១ - ទី៣ ប្រើប្រាស់សម្រាប់ដំណើរការវាយតម្លៃក្នុងដំណាក់កាលទី២ នៃនីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ រួមមានការពិនិត្យសិក្សាឯកសារស្នើសុំ (២.១) និងការចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង (២.២)* | | | | |
| ១. ស្ថិតក្រោមសមត្ថកិច្ចរបស់ក្រសួងបរិស្ថាន | ១.១.ស្ថិតក្នុងតំបន់ការពារធម្មជាតិ | | | - ផ្ទៀងផ្ទាត់ផែនទី<br>- ផ្ទៀងផ្ទាត់ទំហំផ្ទៃដីដែលស្នើសុំ<br>- ពិនិត្យឯកសារទេសន្សនទាន |
| | ១.២.ស្ថិតក្នុងតំបន់ប្រើប្រាស់ដោយចីរភាពនៃតំបន់ការពារធម្មជាតិ | | | - ផ្ទៀងផ្ទាត់ផែនទីនិងសិក្សាឯកសារដែលមានស្រាប់<br>- ពិនិត្យឯកសារទេសន្សនទាន |
| | ១.៣.ស្ថិតក្នុងតំបន់របៀងអភិរក្សជីវៈចម្រុះ | | | - ផ្ទៀងផ្ទាត់ផែនទី<br>- ពិនិត្យឯកសារទេសន្សនទាន |
| ២. អំណោយផល នៃស្ថានភាពភូមិសាស្ត្រ | ២.១.ទីតាំងដែលមានផលប៉ះពាល់តិចតួចបំផុតមកលើធនធានជីវៈចម្រុះ និងប្រព័ន្ធអេកូឡូស៊ីក្នុងតំបន់ការពារធម្មជាតិ | | | - ចុះពិនិត្យជាក់ស្តែង និងកំណត់ពីប្រភេទព្រៃឈើ សត្វព្រៃ ជម្រកធម្មជាតិ ធនធានពន្ធុ និងលក្ខណៈទេសភាពធម្មជាតិនៅក្នុងតំបន់ដែលមានតម្លៃសម្រាប់ការការពារ និងអភិរក្ស (ឧទាហរណ៍៖ ប្រភេទព្រៃឈើ សត្វព្រៃ និងធនធានកម្រជិតផុតពូជទទួលរងគ្រោះថ្នាក់គម្រាមកំហែង និងមានប្រព័ន្ធអេកូឡូស៊ីផុយស្រួយ)<br>- សិក្សាឯកសារ និងរបាយការណ៍ស្រាវជ្រាវ ដែលមានស្រាប់ (ឧទាហរណ៍៖ បញ្ជីក្រហមរបស់អង្គការ IUCN បញ្ជីព្រៃឈើនិងសត្វព្រៃរបស់រដ្ឋបាលព្រៃឈើ។ល។) |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | | | | - ពិនិត្យឯកសារទស្សនទាន |
| | ២.២.ទីតាំងដែលមានចម្ងាយសមស្របពីភូមិករ ឬ ទីប្រជុំជន | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ចម្ងាយពីភូមិករដែលជិតជាងគេទៅដល់ទីតាំងគម្រោង គិតជាគីឡូម៉ែត្រ ស្របតាមស្ថានភាពភូមិសាស្ត្រជាក់ស្តែង<br>- ពិនិត្យឯកសារទស្សនទាន |
| | ២.៣.ទីតាំងដែលមានផ្លូវចេញ-ចូលដល់ | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ប្រភេទមធ្យោបាយធ្វើដំណើរ<br>- មានផ្លូវចាស់ដែលធ្លាប់ធ្វើដំណើរ (ថ្មើរជើង/កង់/ម៉ូតូ/ រថយន្ត។ល។)<br>- ក្នុងករណីមិនមានផ្លូវចាស់ ការរៀបចំផ្លូវត្រូវមានផលប៉ះពាល់តិចតួចបំផុតដល់តំបន់ការពារធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី និងទេសភាពធម្មជាតិ<br>- ពិនិត្យឯកសារទស្សនទាន |
| | ២.៤.ទីតាំងដែលមានប្រភពទឹកសមស្របសម្រាប់ផ្គត់ផ្គង់ | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ចម្ងាយពីទីតាំងទៅប្រភពទឹកដែលមាន<br>- ពិនិត្យឯកសារទស្សនទាន |
| | ២.៥.ទីតាំងដែលមាន ឬ អាចទាញយកបាននូវប្រភពថាមពលសមស្របសម្រាប់ផ្គត់ផ្គង់ និងប្រើប្រាស់ | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ចម្ងាយពីទីតាំងទៅប្រភពថាមពលអគ្គិសនីរដ្ឋ/ឯកជន<br>- ប្រភពថាមពលអគ្គិសនីកកើតឡើងវិញដែលអាច |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | | | | ទាញយកបាននៅលើទីតាំង (ថាមពលពីព្រះអាទិត្យ ចរន្តទឹកហូរ ខ្យល់ ជីវម៉ាស/ឧស្ម័ន ។ល។)<br>- ពិនិត្យឯកសារទស្សនទាន |
| | ២.៦.ទីតាំងដែលមានប្រព័ន្ធសេវាទូរស័ព្ទសម្រាប់ទំនាក់ទំនង | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ប្រព័ន្ធសេវាទូរស័ព្ទដែលគ្របដណ្តប់ក្នុងតំបន់ |
| **៣. សក្តានុពល និងទំហំនៃការអភិវឌ្ឍទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ** | ៣.១.ជាគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិ ដែលមានលក្ខណៈសមស្របនឹងបរិបទតំបន់ការពារធម្មជាតិ ឬ ក្នុងរបៀងអភិរក្សជីវៈចម្រុះ | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ពិនិត្យឯកសារទស្សនទាន និងបទបង្ហាញរបស់ម្ចាស់សំណើ |
| | ៣.២.ជាគម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិបែបកែច្នៃ ដែលមានលក្ខណៈសមស្របនឹងបរិបទតំបន់ការពារធម្មជាតិឬក្នុងរបៀងអភិរក្សជីវៈចម្រុះ | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ពិនិត្យឯកសារទស្សនទាន និងបទបង្ហាញរបស់ម្ចាស់សំណើ |
| | ៣.៣.ផលិតផល និងសេវាកម្មទេសចរណ៍ធម្មជាតិដែលមានលក្ខណៈមេត្រីបរិស្ថាន ឆ្លុះបញ្ចាំងពីវប្បធម៌ក្នុងស្រុក ផ្តល់អាទិភាពដល់ប្រជាជនមូលដ្ឋានចូលរួម និងឈរលើគោលការណ៍គុណភាពនៃបទពិសោធន៍របស់អ្នកទស្សនាជាមូលដ្ឋាន | | | - ពិនិត្យឯកសារទស្សនទាន និងបទបង្ហាញរបស់ម្ចាស់សំណើ |
| | ៣.៤.ប្រភេទសកម្មភាពទេសចរណ៍ធម្មជាតិខ្នាតតូចដែលត្រូវបានអនុញ្ញាតនៅក្នុងតំបន់ការពារធម្មជាតិ ឬ ក្នុងរបៀងអភិរក្សជីវៈចម្រុះ | | | - ពិនិត្យឯកសារទស្សនទាន និងបទបង្ហាញរបស់ម្ចាស់សំណើ<br>- ផ្ទៀងផ្ទាត់នឹងប្រភេទសេវាកម្ម និងសកម្មភាពអនុញ្ញាត និងហេដ្ឋារចនាសម្ព័ន្ធគាំទ្រ |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | ៣.៥. សកម្មភាពអភិវឌ្ឍន៍ និងគម្រោងហេដ្ឋារចនាសម្ព័ន្ធគ្រាំទ្រ ដោយប្រើប្រាស់ទំហំផ្ទៃដីមិនលើសពី ៣០% នៃទំហំផ្ទៃដីសរុបដែលបានស្នើសុំ។ ទំហំផ្ទៃដីដែលនៅសល់ ត្រូវរក្សាទុកក្នុងលក្ខណៈដើម។ | | | - ពិនិត្យឯកសារទស្សនទាន និងបទបង្ហាញរបស់ម្ចាស់សំណើ |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| *កំណត់សម្គាល់៖ លក្ខណៈវិនិច្ឆ័យទី៤ - ទី៧ ប្រើប្រាស់សម្រាប់ដំណើរការបំពេញនីតិវិធីក្នុងដំណាក់កាលទី៣នៃនីតិវិធីសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ជាពិសេសសម្រាប់ការវាយតម្លៃលើការរៀបចំប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ (៣.៣) និងការរៀបចំរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងសង្គម (៣.៤)* | | | | |
| ៤. ប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ សមស្រប និងគាំទ្រ ដល់លក្ខណៈសម្បត្តិ និងគុណតម្លៃធម្មជាតិ និងវប្បធម៌នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ | ៤.១.គំនូរព្រាងទីតាំងមានលក្ខណៈសមស្របទៅនឹងទេសភាពធម្មជាតិក្នុងតំបន់ | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៤.២.ទំហំ និងការរចនាប្លង់អភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធមានលក្ខណៈសាមញ្ញសមស្របនឹងលក្ខខណ្ឌទេសភាពធម្មជាតិក្នុងតំបន់ប្រកបដោយមេត្រីបរិស្ថាននិងចូលរួមលើកកម្ពស់វប្បធម៌ក្នុងស្រុក | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៤.៣.គម្រោងសាងសង់ និងវិធីសាស្ត្រសាងសង់ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍ធម្មជាតិដែលផ្តល់ផលប៉ះពាល់តិចតួចមកលើបរិស្ថាន និងសង្គម | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៤.៤.ផ្តល់អាទិភាពដល់ការប្រើប្រាស់សម្ភារៈ ឬវត្ថុធាតុដើម និងជំនាញដែលមានស្រាប់ក្នុងតំបន់ (រាប់បញ្ចូលផងដែរនូវសិល្បៈហត្ថកម្មក្នុងតំបន់) សម្រាប់ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធនិងសម្បទាទេសចរណ៍ធម្មជាតិ | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៤.៥.ការសន្សំសំចៃថាមពល និងការប្រើប្រាស់ប្រភពថាមពលស្អាតឬកកើតឡើងវិញ និងការបំពាក់ឧបករណ៍បរិក្ខារប្រើប្រាស់ប្រកបដោយមេត្រីបរិស្ថានសម្រាប់គម្រោង | | | - ពិនិត្យឯកសារប្លង់មេនិងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៤.៦.ការគ្រប់គ្រង និងការសន្សំសំចៃទឹក (កាត់បន្ថយ និងប្រើប្រាស់ឡើងវិញ) សម្រាប់គម្រោង | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | ៤.៧.ការគ្រប់គ្រងសំរាម សំណល់រឹង-រាវ និងការបំពុលគ្រប់ប្រភេទ ដោយអនុវត្តទៅតាមលក្ខណៈបច្ចេកទេសនៃកិច្ចគាំពារបរិស្ថាន | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| ៥.ផលប៉ះពាល់តិចតួចពីគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចក្នុងតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ | ៥.១.ប្រតិបត្តិការរបស់គម្រោងអភិវឌ្ឍន៍មានផលប៉ះពាល់អប្បបរមាលើគុណភាព និងគុណតម្លៃនៃតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ និងវប្បធម៌របស់ប្រជាសហគមន៍ | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង<br>- តារាងផ្ទៀងផ្ទាត់វាយតម្លៃហេតុប៉ះពាល់បរិស្ថាន |
| | ៥.២.ម្ចាស់គម្រោងធ្វើការសិក្សាវាយតម្លៃពីដែនកំណត់សមស្របនៃការប្រែប្រួលរបស់តំបន់ពីសកម្មភាពទស្សនា (acceptable limits of change) សម្រាប់ទាំងបរិស្ថានរូបវន្ត និងបរិស្ថានសង្គម ដើម្បីកំណត់ពីទំហំ និងលទ្ធភាពដែលអាចធ្វើទៅបានសម្រាប់ប្រតិបត្តិការគម្រោងនៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង<br>- ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ការចូលរួមពិគ្រោះយោបល់ពីសមត្ថកិច្ចជំនាញ/អាជ្ញាធរពាក់ព័ន្ធ និងប្រជាសហគមន៍ |
| | ៥.៣.ការសិក្សាពីហេតុប៉ះពាល់បរិស្ថាន (មកលើទេសភាពធម្មជាតិ សេវាកម្មប្រព័ន្ធអេកូឡូស៊ី ធនធានជីវៈចម្រុះ និងធនធានធម្មជាតិដទៃទៀត) និងហេតុប៉ះពាល់សង្គម (មកលើមុខរបរចិញ្ចឹមជីវិត ការអាស្រ័យផលពីអនុផលព្រៃឈើ ផ្លូវឆ្លងកាត់ វប្បធម៌ និងការរស់នៅរបស់ប្រជាសហគមន៍ក្នុងតំបន់) ត្រូវបានអនុវត្តឡើងដោយយកចិត្តទុកដាក់ | | | - ចុះពិនិត្យសិក្សាទីតាំងជាក់ស្តែង<br>- ការចូលរួមពិគ្រោះយោបល់ពីសមត្ថកិច្ចជំនាញ/អាជ្ញាធរពាក់ព័ន្ធ |
| | ៥.៤.ការរៀបចំកិច្ចសន្យាការពារបរិស្ថាន ត្រូវភ្ជាប់ជាមួយផែនការគ្រប់គ្រងបរិស្ថាន (Environmental Management Plan) | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងបទបង្ហាញរបស់ម្ចាស់គម្រោង |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | ៥.៥.ការគ្រប់គ្រងសកម្មភាពអ្នកទស្សនានៅក្នុងទីតាំងគម្រោង និងក្នុងទីតាំងដទៃទៀតនៃតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ត្រូវបានដាក់បញ្ចូលក្នុងរបាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ របាយការណ៍វាយតម្លៃហេតុប៉ះពាល់បរិស្ថាន និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៥.៦.គម្រោងមានបុគ្គលិកគ្រប់គ្រាន់ដែលមានគុណវុឌ្ឍិសមស្រប សម្រាប់បំពេញតម្រូវការនៃការគ្រប់គ្រង និងប្រតិបត្តិការក៏ដូចជាសម្រាប់សកម្មភាពការពារ និងអភិរក្សនៅក្នុងតំបន់គម្រោង | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៥.៧.គម្រោងអនុវត្តកម្មវិធីបណ្តុះបណ្តាល កសាងសមត្ថភាពជំនាញ និងបំណិននានា ពាក់ព័ន្ធនឹងគុណភាពសេវាកម្មទេសចរណ៍ធម្មជាតិ និងកិច្ចគាំពារបរិស្ថាន ការការពារ និងអភិរក្សធនធានធម្មជាតិនៅក្នុងទីតាំងគម្រោង និងទីតាំងដទៃទៀតនៃតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| ៦. ប្រតិបត្តិការគម្រោងប្តេជ្ញាអនុវត្ត និងបង្កើតនូវស្នាដៃប្រតិបត្តិល្អៗផ្នែកបរិស្ថាន និងវប្បធម៌នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ | ៦.១.ផលិតផល និងសេវាកម្មទេសចរណ៍ធម្មជាតិរបស់គម្រោងអនុវត្តស្របតាមគោលការណ៍សំខាន់ៗទាំងបីនៃការអភិវឌ្ឍដោយចីរភាព ដោយរួមមានចីរភាពសេដ្ឋកិច្ច ចីរភាពបរិស្ថាន និងចីរភាពសង្គម | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៦.២.ការភ្ជាប់អ្នកពាក់ព័ន្ធ សហគមន៍មូលដ្ឋាន សហគមន៍ជនជាតិដើមភាគតិច ដែលរស់នៅក្នុងនិងជុំវិញតំបន់កាពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ឱ្យចូលរួមគ្រប់ដំណើរការសិក្សាអំពីសេដ្ឋកិច្ចនិងសង្គម និងគ្រប់ដំណាក់កាលអនុវត្តគម្រោង | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៦.៣.គម្រោងផ្តល់ឱកាសប្រកបដោយសមធម៌ដល់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចដែល | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | រស់នៅក្នុងនិងជុំវិញតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ក្នុងការធ្វើការងារ ក៏ដូចជាក្នុងការផ្គត់ផ្គង់សេវាកម្ម/ផលិតផលនានា ដោយទទួលបាននូវប្រាក់កម្រៃសមស្រប | | | |
| | ៦.៤.គម្រោងមានផែនការចូលរួមទប់ស្កាត់នូវសកម្មភាពអ្នកទស្សនាទាំងឡាយ ដែលបង្កផលប៉ះពាល់អវិជ្ជមានដល់វប្បធម៌ក្នុងតំបន់ និងលើកទឹកចិត្តអ្នកទស្សនាឱ្យចូលរួមគោរពស្រឡាញ់វប្បធម៌របស់សហគមន៍មូលដ្ឋាន និងសហគមន៍ជនជាតិដើមភាគតិចដែលរស់នៅក្នុង និងជុំវិញតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ | | | - ពិនិត្យឯកសារប្លង់មេនិងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៦.៥.គម្រោងចូលរួមលើកកម្ពស់កិច្ចសហប្រតិបត្តិការជាមួយអង្គភាពគ្រប់គ្រងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ សំដៅការបង្កើនចំណេះដឹង បទពិសោធន៍អ្នកទស្សនា និងការថែរក្សាគុណតម្លៃធម្មជាតិ និងវប្បធម៌របស់តំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ តាមរយៈការចូលរួមវិភាគទានក្នុងបុព្វហេតុអភិរក្សធនធានធម្មជាតិ | | | - ពិនិត្យឯកសារប្លង់មេនិងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៦.៦.គម្រោងមានសកម្មភាពប្រតិបត្តិ ដែលអាចអនុវត្តបាន ដើម្បីបង្ការ និងកាត់បន្ថយហានិភ័យ និងសម្រាប់គ្រប់គ្រងវិបត្តិនានា | | | - ពិនិត្យឯកសារប្លង់មេនិងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៦.៧.ហេដ្ឋារចនាសម្ព័ន្ធ និងសម្បទាទេសចរណ៍នឹងត្រូវជួសជុលថែរក្សាឱ្យបានសមស្រប និងទៀងទាត់ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អ្នកទស្សនា និងការគ្រប់គ្រងបរិស្ថានក្នុងតំបន់ | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| ៧. រយៈពេល និងសិទ្ធិស្របច្បាប់ និងទទួលស្គាល់ដោយច្បាប់សម្រាប់ប្រតិបត្តិការគម្រោងនឹងស្របជាមួយទំហំ និងអត្រានៃប្រាក់ចំណេញដែលអាចទទួលបានមកវិញពីគម្រោងអភិវឌ្ឍន៍ | ៧.១.គម្រោងអភិវឌ្ឍន៍ទេសចរណ៍ធម្មជាតិអនុលោមតាម និងមានឆន្ទៈគោរពតាមច្បាប់ និងបទបញ្ញត្តិពាក់ព័ន្ធទាំងឡាយដែលទាក់ទងនឹងការប្រើប្រាស់ដីធ្លី ការគ្រប់គ្រងបរិស្ថាន បញ្ហាសុខភាព និងសុវត្ថិភាព បទដ្ឋានគំរូប្លង់ និងការសាងសង់ និងការប្រើប្រាស់ធនធានតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ការចុះបញ្ជីពាណិជ្ជកម្ម និងការស្នើសុំលិខិតអនុញ្ញាត/អាជ្ញាប័ណ្ណធ្វើអាជីវកម្ម នីតិវិធីក្នុងការបង់ពន្ធ និងបទដ្ឋានអនុញ្ញាតសំខាន់ៗដទៃទៀតដែលមានជាធរមានក្នុងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង<br>- ពិនិត្យពីនីតិវិធី និងដំណើរការសំខាន់ៗដទៃទៀតដែលបានបំពេញដោយម្ចាស់គម្រោង |
| | ៧.២.គម្រោងមានកម្មវិធីអភិវឌ្ឍន៍ច្បាស់លាស់ ដែលបញ្ជាក់ពីដំណាក់កាលសកម្មភាព និងពេលវេលាជាក់លាក់ ដែលអាចឆ្លើយតបបាននឹងតម្រូវការអភិវឌ្ឍន៍ ការគ្រប់គ្រង និងប្រតិបត្តិការក្នុងរយៈពេលចុះកិច្ចសន្យាប្រើប្រាស់ទីតាំង | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៧.៣.គម្រោងមានផែនការហិរញ្ញវត្ថុសម្រាប់អភិវឌ្ឍន៍ ដែលមានលក្ខណៈវិជ្ជមាន និងបង្ហាញពីលទ្ធភាពក្នុងការទទួលបានមកវិញនូវប្រាក់ចំណេញពីការអភិវឌ្ឍ | | | - ពិនិត្យឯកសារប្លង់មេនិងកម្មវិធីអភិវឌ្ឍន៍ និងបទបង្ហាញរបស់ម្ចាស់គម្រោង |
| | ៧.៤.ពិនិត្យលទ្ធភាពលើការវិភាគពីផលប្រយោជន៍សេដ្ឋកិច្ច និងមិនមែនសេដ្ឋកិច្ច ដែលមានលទ្ធផលវិជ្ជមានសម្រាប់ទាំងការអភិវឌ្ឍរបស់គម្រោង និងប្រជាសហគមន៍ និងជនជាតិដើមភាគតិចដែលរស់នៅក្នុង និងជុំវិញតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ | | | - ពិនិត្យឯកសារប្លង់មេនិងកម្មវិធីអភិវឌ្ឍន៍ |

| លក្ខណៈវិនិច្ឆ័យ | សូចនាករសម្រាប់វិនិច្ឆ័យ | បាទ/ចាស | ទេ | វិធីសាស្ត្រវិនិច្ឆ័យ |
|---|---|---|---|---|
| | ៧.៥. គម្រោងប្រើប្រាស់ផ្នែកនៃប្រាក់ចំណេញ សម្រាប់ធ្វើឱ្យប្រសើរឡើងការការពារ និងការអភិរក្ស និងការអភិវឌ្ឍគម្រោងប្រកបដោយចីរភាព | | | - ពិនិត្យឯកសារប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ កិច្ចសន្យាប្រើប្រាស់ទីតាំង កិច្ចសន្យាវាយតម្លៃផលហេតុប៉ះពាល់បរិស្ថាន |

**សម្គាល់៖**

- *ទេសចរណ៍ធម្មជាតិ ឬ ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ(បរិបទតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ និងសហគមន៍តំបន់ការពារធម្មជាតិ)* សំដៅដល់ការធ្វើដំណើរទេស្សនា ឬ សេវាកម្ម និងសកម្មភាពទេសចរណ៍នានាក្នុងតំបន់ការពារធម្មជាតិ របៀងអភិរក្សជីវៈចម្រុះ ឬ ក្នុងសហគមន៍តំបន់ការពារធម្មជាតិ ដែលបង្កផលប៉ះពាល់អប្បបរមាដល់បរិស្ថានធម្មជាតិក្នុង និងជុំវិញតំបន់ទេសចរណ៍ និងមានគោលដៅបម្រើឱ្យសកម្មភាពអភិរក្ស លើកកម្ពស់ការយល់ដឹង និងការស្រឡាញ់ធម្មជាតិ និងវប្បធម៌ក្នុងតំបន់ និងផ្តល់ផលប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចមូលដ្ឋាន ប្រកបដោយនិរន្តរភាព។
- **ផលប៉ះពាល់អប្បបរមា-** សំដៅលើផលប៉ះពាល់ ឬ សកម្មភាពដែលធ្វើឱ្យមានបម្រែបម្រួលតិចតួចមកលើធនធានជីវៈចម្រុះ ប្រព័ន្ធអេកូឡូស៊ី ទេសភាពធម្មជាតិ លក្ខខណ្ឌបរិស្ថាន ទិដ្ឋភាព ឬបរិស្ថានជុំវិញក្នុងតំបន់ លក្ខណៈសម្បត្តិ និងគុណតម្លៃសង្គម-វប្បធម៌នៅក្នុងតំបន់ បទពិសោធន៍ និងគុណភាពទស្សនារបស់ភ្ញៀវទេសចរ ការចំណាយសម្រាប់ការរស់នៅរបស់ប្រជាជនមូលដ្ឋាន សមត្ថភាពដែលអាចទទួលបានរបស់តំបន់ កិច្ចគាំពារបរិស្ថាន និងការអភិរក្ស និងសមត្ថភាពលទ្ធភាពសម្រាប់ការអភិវឌ្ឍ និងកំណើនសេដ្ឋកិច្ចកម្រិតមូលដ្ឋាន និងក្នុងតំបន់។

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

## កិច្ចសន្យា
## ស្តីពី
## ការប្រើប្រាស់ទីតាំងសម្រាប់អនុវត្តគម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចដែលមានទំហំផ្ទៃដីក្រោម ១០(ដប់) ហិកតា នៅក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ

ខ្ញុំបាទ/នាងខ្ញុំឈ្មោះ.......................... កើតនៅថ្ងៃទី..... ខែ....... ឆ្នាំ.......... សញ្ជាតិខ្មែរ កាន់អត្តសញ្ញាណប័ណ្ណលេខ....................... អាស័យដ្ឋានបច្ចុប្បន្នភូមិ............ ឃុំ/សង្កាត់.............. ស្រុក/ក្រុង................... រាជធានី/ខេត្ត.......................... ជានាយកក្រុមហ៊ុន.............................. លេខទូរស័ព្ទទំនាក់ទំនង..........................................។

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន

**យោង៖** - លិខិតលេខ ៥៥១ សជណ.កស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- លិខិតលេខ ......... សជណ.បស្ត ចុះថ្ងៃទី....... ខែ......ឆ្នាំ........... របស់ក្រសួងបរិស្ថាន
- លិខិតលេខ............ ចុះថ្ងៃទី......... ខែ............ ឆ្នាំ២០២១ របស់ក្រុមហ៊ុន................

ដើម្បីធានាបាន នូវដំណើរការអនុវត្តគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចលើផ្ទៃដីទំហំ .......................... (...............................) ដែលមានផែនទី និងនិយាមកាភ្ជាប់មកជាមួយស្ថិតក្នុង.................................. ភូមិសាស្ត្រភូមិ................ ឃុំ/សង្កាត់.................. ស្រុក/ក្រុង............................រាជធានី/ខេត្ត............................. ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ សូមគោរព និងអនុវត្តតាមទាំងស្រុង ដូចមានចែងក្នុងប្រការខាងក្រោម៖

**ប្រការ ១**.-

ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំត្រូវអនុវត្តកាតព្វកិច្ចតាមចំណុច ដូចខាងក្រោម៖

- អនុវត្តគម្រោងស្របទៅតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍
- គ្រប់គ្រងសំរាម សំណល់រឹង-រាវគ្រប់ប្រភេទ ដោយអនុវត្តទៅតាមលក្ខណៈបច្ចេកទេសនៃកិច្ចគាំពារបរិស្ថាន
- សាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្បទាទេសចរណ៍ធម្មជាតិ ស្របទៅតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ ដោយអនុវត្តស្របទៅតាមបទដ្ឋានបច្ចេកទេស បទដ្ឋានបរិស្ថាន និងនីតិវិធីច្បាប់ជាធរមាន
- ការពារមិនឱ្យភ្លើងឆេះព្រៃ និងរៀបចំឱ្យមានប្រព័ន្ធការពារអគ្គិភ័យ ដូចជាឧបករណ៍ពន្លត់អគ្គិភ័យគ្រប់គ្រាន់

- គ្រប់គ្រងការបំពុលដោយសំឡេងរំខាន
- មិនបរបាញ់ ឬ ជួញដូរសត្វព្រៃ និងមិនយកសត្វព្រៃគ្រប់ប្រភេទមកបរិភោគ ឬ ប្រើប្រាស់ គ្រប់គ្រង អាស្រ័យផល ឬ ចាត់ចែងទោះក្នុងរូបភាពណាក៏ដោយ
- មិនត្រូវកាប់រានព្រៃឈើ ដែលមានទំហំចាប់ពី ................. នៅក្នុងទីតាំងដោយគ្មានការអនុញ្ញាតជាមុនពីក្រសួងបរិស្ថានឡើយ
- ទទួលខុសត្រូវចំពោះមុខច្បាប់ ក្នុងករណីដែលមានអគ្គិភ័យ ឬបទល្មើសកើតឡើងនៅលើទីតាំង ដែលបង្កដោយក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ឬបុគ្គលិក ឬបុគ្គលដែលស្ថិតក្រោមការគ្រប់គ្រងរបស់ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ
- រាយការណ៍ជូនស្ថាប័ន/អាជ្ញាធរមានសមត្ថកិច្ចពាក់ព័ន្ធ នៅពេលប្រទះឃើញធនធានរ៉ែធម្មជាតិគ្រប់ប្រភេទ មានជាអាទិ៍ រ៉ែដែក ប្រេងកាត អ៊ីដ្រូកាបូន ត្បូង និងធនធានធម្មជាតិដទៃទៀតដែលមាននៅលើឬក្រោមដី។
- សហការ និងរាយការណ៍ដល់មន្ទីរបរិស្ថានខេត្តគោលដៅ និងមន្ត្រីឧទ្យានុរក្សពីសកម្មភាពបទល្មើសនានា ដូចជា៖ ការទន្ទ្រានដី ការបរបាញ់សត្វព្រៃ ការកាប់រានព្រៃឈើ ជាដើម។

**ប្រការ ២.-**

ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ មិនធ្វើការទន្ទ្រាន ឬ កាន់កាប់យកដីបន្ថែមលើសពីទំហំផ្ទៃដីដែលទទួលបានគោលការណ៍អនុញ្ញាតពីក្រសួងបរិស្ថានឡើយ។

**ប្រការ ៣.-**

- ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំពុំមានសិទ្ធិផ្ទេរ ឬ ជួលទីតាំង ទោះទាំងស្រុងឬមួយផ្នែក ទៅតតិយជនគ្រប់គ្រងបន្ត ដោយគ្មានការអនុញ្ញាតជាមុនជាលាយលក្ខណ៍អក្សរពីក្រសួងបរិស្ថានឡើយ។
- ក្នុងករណីក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ មានបំណងសហការជាមួយតតិយជន លុះត្រាណាក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ បានអនុវត្តតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ចាប់ពី ៣០% និងមានការឯកភាពជាមុនជាលាយលក្ខណ៍អក្សរពីក្រសួងបរិស្ថាន ដោយក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ នៅតែជាអ្នកទទួលខុសត្រូវអនុវត្តកិច្ចសន្យាដោយផ្ទាល់ជាមួយក្រសួងបរិស្ថាន។

**ប្រការ ៤.-**

ក្នុងករណីក្រសួងបរិស្ថានតម្រូវឱ្យក្រុមហ៊ុន ធ្វើការកែប្រែនូវបច្ចេកទេសបរិស្ថានណាមួយ ដើម្បីឱ្យសមស្របទៅតាមគោលការណ៍ណែនាំ និងកម្រិតបទដ្ឋានបរិស្ថាន ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំត្រូវអនុវត្តទៅតាមគោលការណ៍ណែនាំនោះទាំងស្រុង និងដោយឥតលក្ខខណ្ឌ។

**ប្រការ ៥.-**

- ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំត្រូវសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្បទាទេសចរណ៍ធម្មជាតិស្របតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ដែលក្រសួងបានអនុម័ត។

- ករណីមានការកែប្រែហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងសម្បទាទេសចរណ៍ធម្មជាតិ ឬ សាងសង់បន្ថែម ក្រុមហ៊ុនត្រូវស្នើសុំការអនុញ្ញាតជាមុនពីក្រសួងបរិស្ថាន ស្ថាប័ន អង្គភាព និងអាជ្ញាធរពាក់ព័ន្ធ។

**ប្រការ ៦**.-

ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ត្រូវសហការ និងសម្របសម្រួលជូនមន្ត្រីជំនាញពីក្រសួងបរិស្ថាន មន្ទីរបរិស្ថានខេត្ត និងមន្ត្រីប្រចាំការក្នុងតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ចេញ-ចូល ធ្វើការត្រួតពិនិត្យ ណែនាំបច្ចេកទេស និងបទបញ្ជាផ្សេងៗ ក្នុងទីតាំងគម្រោងអភិវឌ្ឍន៍គ្រប់ពេលវេលា។

**ប្រការ ៧**.-

- ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ស្ម័គ្រចិត្តចូលរួមបង់វិភាគទាននៅច្រកចេញ-ចូលតែមួយរបស់ក្រសួងបរិស្ថាន ចូលក្នុងមូលនិធិទាយជ្ជទានបរិស្ថានសម្រាប់ការស្តារកែលម្អតំបន់ការពារធម្មជាតិ និងរបៀងអភិរក្សជីវៈចម្រុះ ស្របតាមប្រកាសអន្តរក្រសួងលេខ ១០៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវទឹកប្រាក់សរុបចំនួន.................USD (.....................) ក្នុងមួយឆ្នាំ។
- ថវិកានេះ ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ត្រូវបង់ជូនក្រសួងបរិស្ថាននៅសប្តាហ៍ទី១ នៃខែមករា ជារៀងរាល់ឆ្នាំ។

**ប្រការ ៨**.-

ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ត្រូវបង់សេវាសាធារណៈលើការរៀបចំកិច្ចសន្យាគម្រោងវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិ (ទំហំ<100 ហិកតា) ស្របតាមប្រកាសអន្តរក្រសួងលេខ ១០៧០ សហវ.ប្រក ចុះថ្ងៃទី១៣ ខែវិច្ឆិកា ឆ្នាំ២០២១ រវាងក្រសួងបរិស្ថាន និងក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ នូវទឹកប្រាក់ចំនួន ៨ ០០០ ០០០ រៀលជូនក្រសួងបរិស្ថាននៅច្រក ចេញ-ចូល តែមួយ។

**ប្រការ ៩**.-

ការបង់ពន្ធដារ និងពន្ធប៉ាតង់ផ្សេងៗ ជាអាទិ៍ ទៅតាមដែលច្បាប់បានកំណត់ ត្រូវជាបន្ទុក និងបង់ទាំងស្រុងដោយក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ។ ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំត្រូវបង់ពន្ធទាំងនេះ ឱ្យបានត្រឹមត្រូវ និងទាន់ពេលវេលា។

**ប្រការ ១០**.-

ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ សូមគោរពស្នើសុំកាលបរិច្ឆេទនៃការចុះហត្ថលេខាបានឃើញ និងឯកភាពពីក្រសួងបរិស្ថានលើកិច្ចសន្យានេះ គឺជាកាលបរិច្ឆេទនៃការប្រគល់ទីតាំង ដើម្បីចាប់ផ្តើមចូលសិក្សារៀបចំប្លង់មេ និងកម្មវិធីអភិឌ្ឍន៍។

**ប្រការ ១១**.-

ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ត្រូវរៀបចំប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ឱ្យបានយ៉ាងយូរយៈពេល៦០ថ្ងៃ

នៃថ្ងៃធ្វើការ គិតចាប់ពីកាលបរិច្ឆេទដូចមានចែងក្នុងប្រការ១០ ដើម្បីដាក់ជូនក្រសួងបរិស្ថានពិនិត្យ និងអនុម័ត មុនចាប់ផ្តើមដំណើរការអនុវត្តគម្រោង។

**ប្រការ ១២.-**

ក្នុងករណីក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំមិនបានគោរព និងអនុវត្តតាមកិច្ចសន្យា ឬ អនុវត្តផ្ទុយពីកិច្ចសន្យានេះ ក្រសួងបរិស្ថានមានសិទ្ធិបញ្ចប់កិច្ចសន្យានេះ ដោយមិនទទួលខុសត្រូវលើសំណងណាមួយ ហើយក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ ត្រូវប្រគល់ទីតាំងជូនក្រសួងបរិស្ថាន និងទទួលខុសត្រូវស្តារការខូចខាតលើធនធានធម្មជាតិ ដោយគ្មានការយឺតយ៉ាវ ស្របតាមលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាធរមាន។ ដើម្បីជាការបញ្ជាក់ ការណ៍នេះនឹងមិននាំឱ្យក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ រួចផុតពីការទទួលខុសត្រូវទាំងឡាយចំពោះតតិយជន ស្ថាប័នរដ្ឋ និង/ឬអាជ្ញាធរមានសមត្ថកិច្ច នូវទង្វើ ឬ សកម្មភាព ដែលក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំបានបង្កឡើងឡើយ។

**ប្រការ ១៣.-**

កិច្ចសន្យានេះ មានសុពលភាពរយៈពេល ១៥ (ដប់ប្រាំ) ឆ្នាំ គិតចាប់ពីថ្ងៃចុះហត្ថលេខាបានឃើញនិងឯកភាពពីក្រសួងបរិស្ថានតទៅ។ ករណីក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ មានបំណងបន្តសុពលភាព ឬបញ្ចប់សុពលភាពនៃកិច្ចសន្យានេះ ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ នឹងស្នើសុំការអនុញ្ញាតជាលាយលក្ខណ៍អក្សរមកក្រសួងបរិស្ថានឱ្យបានមុន ០២ (ពីរ) ឆ្នាំ នៃឆ្នាំផុតសុពលភាពនៃអាណត្តិកិច្ចសន្យានេះ។ ករណីបន្តសុពលភាពនៃកិច្ចសន្យាអាចធ្វើទៅបានអាស្រ័យលើលទ្ធផលនៃការវាយតម្លៃ និងការសម្រេចរបស់ក្រសួងបរិស្ថាន។

ក្នុងករណីក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំ មិនអនុវត្តគម្រោងតាមប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍ក្រសួងបរិស្ថានមានសិទ្ធិបញ្ចប់កិច្ចសន្យានេះគ្រប់ពេលវេលា ដោយគ្រាន់តែធ្វើការជូនដំណឹងជាមុន .......... (.....) ខែ និងដោយមិនទទួលខុសត្រូវលើសំណងណាមួយ។

នៅពេលបញ្ចប់កិច្ចសន្យានេះ ក្រុមហ៊ុនខ្ញុំបាទ/នាងខ្ញុំត្រូវប្រគល់ទីតាំងជូនក្រសួងបរិស្ថាន និងទទួលខុសត្រូវស្តារការខូចខាតលើធនធានធម្មជាតិ ដោយគ្មានការយឺតយ៉ាវស្របតាមលិខិតបទដ្ឋានគតិយុត្ត និងច្បាប់ជាធរមាន។

**ប្រការ ១៤.-**

កិច្ចសន្យានេះ ក្រុមហ៊ុនធ្វើជាលាយលក្ខណ៍អក្សរចំនួន ០៨ (ប្រាំបី)ច្បាប់ និងមានចំនួន១៤ (ដប់បួន)ប្រការ ដែលត្រូវតម្កល់ទុកនៅ៖

- ក្រសួងបរិស្ថាន ចំនួន ០២(ពីរ)ច្បាប់
- រដ្ឋបាលខេត្ត ចំនួន ០១(មួយ)ច្បាប់
- អគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន ចំនួន ០១(មួយ)ច្បាប់
- អគ្គនាយកដ្ឋានតំបន់ការពារធម្មជាតិ ចំនួន ០១(មួយ)ច្បាប់

- មន្ទីរបរិស្ថានខេត្ត ចំនួន ០១(មួយ)ច្បាប់
- សាមីក្រុមហ៊ុន ចំនួន ០២(ពីរ) ច្បាប់

ថ្ងៃ ខែ ឆ្នាំ..................ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២...

**ប្រធានក្រុមហ៊ុន**

លេខ៖.......................កស.អសម.បស្ក

បានឃើញ និងសូមគោរពជូន

**ឯកឧត្តមរដ្ឋមន្ត្រី**

«មេត្តាពិនិត្យ និងសម្រេចដោយក្តីអនុគ្រោះ»

ថ្ងៃ.............ខែ................ឆ្នាំ..............ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី............ខែ..............ឆ្នាំ២០២...

**អគ្គនាយកនៃអគ្គនាយកដ្ឋានសហគមន៍មូលដ្ឋាន**

បានឃើញ និងឯកភាព

ថ្ងៃ...............ខែ.............ឆ្នាំ...............ព.ស.២៥៦...

រាជធានីភ្នំពេញ ថ្ងៃទី ខែ ឆ្នាំ២០២...

**រដ្ឋមន្ត្រី**

# ទម្រង់នៃការរៀបចំប្លង់មេ និងកម្មវិធីអភិវឌ្ឍន៍
# ប្រភេទ A4 និងអនុលោមតាមគោលការណ៍ណែនាំរបស់ក្រសួងបរិស្ថាន

## មាតិកា

### ១. សេចក្តីផ្តើម

- បរិយាយអំពីបរិបទគោលនយោបាយ សេដ្ឋកិច្ច-សង្គម និន្នាការរីកចម្រើននៃអនុវិស័យទេសចរណ៍ធម្មជាតិ សក្តានុពល និងឱកាស និងសង្ខេបអំពីគម្រោងទាំងមូល
- ត្រឹមតែ១ទំព័រ

### ២. ចក្ខុវិស័យនៃការអភិវឌ្ឍទេសចរណ៍ធម្មជាតិ

- បញ្ជាក់ពីគោលបំណង ទិសដៅ និងចំណុចអាទិភាពនៃការអភិវឌ្ឍទៅថ្ងៃអនាគត
- គោលការណ៍ និងគុណតម្លៃនៃការអភិវឌ្ឍ

### ៣. យុទ្ធសាស្ត្រនៃការអភិវឌ្ឍទេសចរណ៍ធម្មជាតិ

- កំណត់អត្តសញ្ញាណចំណែកទីផ្សារ អាទិភាពទីផ្សារ និងយុទ្ធសាស្ត្រទីផ្សារ
- កំណត់ការអភិវឌ្ឍប្រភេទផលិតផល សេវាកម្ម និងសកម្មភាពសក្តានុពល
- ការធ្វើសន្ទស្សន៍តម្រូវការទីផ្សារ
- ពង្រឹង និងបង្កើនសោភ័ណភាព និងភាពទាក់ទាញក្នុងតំបន់គម្រោង
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍
- យុទ្ធសាស្ត្រគ្រប់គ្រងបែបនិរន្តរភាព និងមេត្រីបរិស្ថាន

### ៤. និដ្ឋភាពច្បាប់

- លេខ ៥៥១ សជណ.កស ចុះថ្ងៃទី០៤ ខែកក្កដា ឆ្នាំ២០១៧ របស់ទីស្តីការគណៈរដ្ឋមន្ត្រី
- សជណ អនុញ្ញាតជាគោលការណ៍
- សជណ បោះបង្គោលព្រំ
- កិច្ចសន្យាប្រើប្រាស់ទីតាំង

### ៥. ទីតាំងភូមិសាស្ត្រ

- ផែនទីបង្ហាញភូមិសាស្ត្រគម្រោង
- ផែនទីបង្ហាញទីតាំងគម្រោង
- រូបភាពបង្ហាញទីតាំងគម្រោងជាក់ស្តែង

### ៦. ការបែងចែកតំបន់

- ប្លង់ទិដ្ឋភាពរួមនៃការប្រើប្រាស់ដី (ទំហំអភិវឌ្ឍន៍មិនលើសពី ៣០% នៃទំហំផ្ទៃដីរួម)
- ប្លង់បែងចែកតំបន់ និងការប្រើប្រាស់ដី (ឧទាហរណ៍៖ តំបន់បដិសណ្ឋារកិច្ច តំបន់ស្នាក់នៅ តំបន់កម្សាន្ត តំបន់អភិរក្ស...)

- ការរៀបចំប្រព័ន្ធផ្លូវ
- ការរៀបចំប្រព័ន្ធផ្គត់ផ្គង់ទឹកស្អាត
- ការរៀបចំប្រព័ន្ធបណ្តាញអគ្គិសនី និងបរិក្ខារគ្រឿងទទួល
- ការរៀបចំប្រព័ន្ធចម្រោះទឹកកខ្វក់ និងប្រព័ន្ធលូ
- ការរៀបចំគ្រប់គ្រងសំរាម សំណល់រឹង
- ការរៀបចំប្រព័ន្ធសុវត្ថិភាព និងការគ្រប់គ្រងអគ្គិភ័យ

## ៧. កម្មវិធីអភិវឌ្ឍន៍ និងផែនការហិរញ្ញវត្ថុ

- កម្មវិធីអភិវឌ្ឍន៍ដំណាក់កាលទី១ ទី២ ទី៣....
- ផែនការហិរញ្ញវត្ថុ ដោយដាក់បញ្ចូលផងដែរនូវការចំណាយសម្រាប់ការវិនិយោគអភិវឌ្ឍន៍ ប្រភពប្រាក់ចំណូល ប្រាក់ចំណេញដុល ការចំណាយប្រតិបត្តិការ ប្រាក់ចំណេញសុទ្ធ រំលោះ ជាដើម។

## ៨. លក្ខខណ្ឌនៃការអភិវឌ្ឍ

## ៩. ឧបសម្ព័ន្ធ

- ឯកសារយោងពាក់ព័ន្ធ

# ទម្រង់នៃការរៀបចំឯកសារទស្សនទានជាលក្ខណៈបទបង្ហាញ

## មាតិកា

### ១. សេចក្តីផ្តើម

- បរិយាយសង្ខេបអំពីចំណាប់អារម្មណ៍ និងបទពិសោធន៍នៃការអភិវឌ្ឍ
- ទម្រង់ ឬ គំរូនៃគម្រោងអភិវឌ្ឍន៍ដែលស្នើសុំ

### ២. ចក្ខុវិស័យនៃការអភិវឌ្ឍទេសចរណ៍ធម្មជាតិ

- បញ្ជាក់ពីគោលបំណង ទិសដៅ និងចំណុចអាទិភាពនៃការអភិវឌ្ឍទៅថ្ងៃអនាគត (សង្ខេប)
- គោលការណ៍ និងគុណតម្លៃនៃការអភិវឌ្ឍ(សង្ខេប)

### ៣. ផលិតផល សេវាកម្ម និងទីផ្សារគោលដៅ

- បញ្ជាក់អំពីលក្ខណៈសម្បត្តិសំខាន់ៗនៃទីតាំងស្នើសុំ សម្រាប់ប្រភេទនៃការអភិវឌ្ឍ (សង្ខេប)
- បង្កើតសោភ័ណភាព និងភាពទាក់ទាញក្នុងតំបន់គម្រោងស្នើសុំ(សង្ខេប)
- ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងសេវាកម្មទេសចរណ៍(សង្ខេប)
- ការកំណត់អត្តសញ្ញាណទីផ្សារ និងសកម្មភាព
- ប្រភេទផលិតផលទេសចរណ៍ដែលមាន និងសកម្មភាពពាក់ព័ន្ធ (សង្ខេប និងរូបភាព)

### ៤. ទីតាំងភូមិសាស្ត្រ

- ផែនទីបង្ហាញភូមិសាស្ត្រគម្រោងស្នើសុំ
- ផែនទីបង្ហាញទីតាំងគម្រោងស្នើសុំ
- រូបភាពបង្ហាញទីតាំងគម្រោងស្នើសុំជាក់ស្តែង

### ៥. ការបែងចែកតំបន់

- ប្លង់ទិដ្ឋភាពរួមនៃការប្រើប្រាស់ដី (ទំហំអភិវឌ្ឍន៍មិនលើសពី ៣០% នៃទំហំផ្ទៃដីរួម)
- ប្លង់បែងចែកតំបន់ និងការប្រើប្រាស់ដី (ឧទាហរណ៍៖ តំបន់បដិសណ្ឋារកិច្ច តំបន់ស្នាក់នៅ តំបន់កម្សាន្ត តំបន់អភិរក្ស...)

### ៦.ផែនការសកម្មភាព ទុនវិនិយោគ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

៣៣❁៩៩

ខ្ញុំបាទ/នាងខ្ញុំ ឈ្មោះ.................... ភេទ........ កើតនៅថ្ងៃទី..... ខែ......... ឆ្នាំ........... កាន់អត្តសញ្ញាណប័ណ្ណលេខ ................................................. មានទីលំនៅបច្ចុប្បន្ន ផ្ទះលេខ............. ផ្លូវ........... ភូមិ..............ឃុំ/សង្កាត់..................... ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត............................។

**សូមគោរពជូន**

**ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន**

**កម្មវត្ថុ ៖** សំណើសុំវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ស្ថិតក្នុង................ ................................................................................................................

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំបាទ/នាងខ្ញុំមានកិត្តិយសសូមគោរពជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយពិនិត្យឃើញទីតាំងខាងលើមានសក្តានុពលខ្ពស់លើវិស័យទេសចរណ៍ធម្មជាតិ ខ្ញុំបាទ/នាងខ្ញុំ ស្នើសុំការអភិវឌ្ឍគម្រោងទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ក្នុងគោលបំណងរួមចំណែកលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជំរុញនូវកំណើនសេដ្ឋកិច្ចជាតិតាមរយៈវិស័យទេសចរណ៍។ គម្រោងទេសចរណ៍នេះ ខ្ញុំបាទ/នាងខ្ញុំនឹងរៀបចំជាទីកន្លែងផ្តល់នូវសេវាកម្មទេសចរណ៍រួមមាន៖...........................................................................................................។

ក្នុងនោះផងដែរ ខ្ញុំបាទ/នាងខ្ញុំ សូមធានាថានឹងអនុវត្តគម្រោងវិនិយោគទេសចរណ៍ធម្មជាតិនេះប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅអាជីវកម្ម។

ដូច្នេះ ខ្ញុំបាទ/នាងខ្ញុំ សូមគោរព **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាអនុញ្ញាតជាគោលការណ៍លើគម្រោងស្នើសុំវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ត្រង់ចំណុចនិយាមកាលេខ ............... ..........................ស្ថិតក្នុង.......................................................................... ដោយក្តីអនុគ្រោះ។

សេចក្តីដូចបានគោរពជម្រាបខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេច។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដោយស្មោះពីខ្ញុំបាទ/នាងខ្ញុំ។

ថ្ងៃ................ខែ............ឆ្នាំ...................ព.ស.២៥៦...

..................ថ្ងៃទី.........ខែ...........ឆ្នាំ.................

**ហត្ថលេខា ឬ ស្នាមមេដៃស្តាំម្ចាស់សំណើ**

សូមភ្ជាប់ជូនឯកសារ៖

- ផែនទី និងនិយាមកា
- អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរ(ចំពោះរូបវន្តបុគ្គល)
- ឯកសារចុះបញ្ជីក្រុមហ៊ុន
- ឯកសារទេស្សនៈទាន

# ព្រះរាជាណាចក្រកម្ពុជា
# ជាតិ សាសនា ព្រះមហាក្សត្រ

៣៣✵៥៥

ក្រុមហ៊ុន.............................................. ជាក្រុមហ៊ុនដែលបានចុះបញ្ជីស្របតាមច្បាប់ព្រះរាជាណាចក្រកម្ពុជា មានអត្តលេខចុះបញ្ជីពាណិជ្ជកម្មលេខ ....................... ចុះថ្ងៃទី........ ខែ.............ឆ្នាំ......... ដែលមានទីស្នាក់ការនៅផ្ទះលេខ................ ភូមិ........... ឃុំ/សង្កាត់............. ស្រុក/ខណ្ឌ................ រាជធានី/ខេត្ត................. តំណាងដោយលោក/លោកស្រី ........................... កើតនៅថ្ងៃទី........ ខែ....... ឆ្នាំ......... កាន់អត្តសញ្ញាណប័ណ្ណសញ្ជាតិខ្មែរលេខ ............................... ចុះថ្ងៃទី........ ខែ............. ឆ្នាំ................. មានតួនាទីជា...........................

## សូមគោរពជូន
## ឯកឧត្តមរដ្ឋមន្ត្រីក្រសួងបរិស្ថាន

**កម្មវត្ថុ ៖** សំណើសុំវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ស្ថិតក្នុង................ ........................................................................................................................

សេចក្តីដូចបានគោរពជូនក្នុងកម្មវត្ថុខាងលើ យើងខ្ញុំមានកិត្តិយសសូមជម្រាបជូន **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាជ្រាបថា ដោយពិនិត្យឃើញទីតាំងខាងលើមានសក្តានុពលខ្ពស់លើវិស័យទេសចរណ៍ធម្មជាតិ យើងខ្ញុំមានបំណងចូលរួមក្នុងការអភិវឌ្ឍគម្រោងទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ក្នុងគោលបំណងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាសហគមន៍មូលដ្ឋាន និងជំរុញនូវកំណើនសេដ្ឋកិច្ចជាតិ តាមរយៈវិស័យទេសចរណ៍។ គម្រោងទេសចរណ៍នេះ យើងខ្ញុំនឹងរៀបចំជាទីកន្លែងផ្តល់នូវសេវាកម្មទេសចរណ៍រួមមាន.................................................................................................................................។

ក្នុងនោះផងដែរ យើងខ្ញុំសូមធានាថានឹងអនុវត្តគម្រោងវិនិយោគទេសចរណ៍ធម្មជាតិនេះប្រកបដោយជោគជ័យ និងសម្រេចបាននូវគោលដៅអាជីវកម្ម។

ដូច្នេះ យើងខ្ញុំសូមគោរព **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាអនុញ្ញាតជាគោលការណ៍លើគម្រោងស្នើសុំវិនិយោគអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូច ត្រង់ចំណុចនិយាមកាលេខ ............... .........................ស្ថិតក្នុង............................................................................................ ដោយក្តីអនុគ្រោះ។

សេចក្តីដូចបានគោរពជម្រាបខាងលើ សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាពិនិត្យ និងសម្រេច។

សូម **ឯកឧត្តមរដ្ឋមន្ត្រី** មេត្តាទទួលនូវការគោរពដោយស្មោះពីយើងខ្ញុំ។

ថ្ងៃ................ខែ............ឆ្នាំ...................ព.ស.២៥៦...

...................ថ្ងៃទី.........ខែ............ឆ្នាំ.................

**ហត្ថលេខា និង ត្រារបស់ក្រុមហ៊ុន**

សូមភ្ជាប់ជូនឯកសារ៖

- ផែនទី និងនិយាមកា
- ឯកសារចុះបញ្ជីក្រុមហ៊ុន
- ឯកសារទេសន្ទនៈទាន

# ប្រភេទ
# សេវាកម្ម និងសកម្មភាពសមស្របសម្រាប់គម្រោងអភិវឌ្ឍន៍ទេសចរណ៍ផ្សារភ្ជាប់នឹងធម្មជាតិខ្នាតតូចដែលមានទំហំផ្ទៃដីក្រោម ១០(ដប់) ហិកតា ក្នុងតំបន់ការពារធម្មជាតិ និង របៀងអភិរក្សជីវៈចម្រុះ

## ១. ប្រភេទសេវាកម្ម៖

- **សេវាកម្មស្នាក់នៅ** (អេកូឡូច ជំរុំបោះតង់ចល័តនិងអចិន្ត្រៃយ៍ ផ្ទះដើមឈើ កន្លែងវិបស្សនា និងក្លិបយូហ្គា ជំរុំការ៉ាវ៉ាន់ខ្នាតតូច ផ្ទះសំណាក់ឧទ្យានុរក្ស ផ្ទះសំណាក់សហគមន៍ ផ្ទះស្នាក់បូករួមអាហារពេលព្រឹករបស់ប្រជាសហគមន៍ ផ្ទះស្នាក់ ។ល។)
- **សេវាកម្មអាហារនិងភេសជ្ជៈ** (ហាងកាហ្វេ និងភោជនីយដ្ឋានខ្នាតតូច ផ្ទះបាយឧទ្យានុរក្ស ផ្ទះបាយសហគមន៍ ផ្ទះស្នាក់បូករួមអាហារពេលព្រឹករបស់ប្រជាសហគមន៍ ម៉ាស៊ីនលក់ស្វ័យប្រវត្តិដែលប្រើថាមពលនិងបច្ចេកវិទ្យាបៃតង តំបន់ឬទីតាំងបើកចំហ សម្រាប់ស្រស់ស្រូបអាហារ តូបអាហារធ្វើពីឈើ/ឬស្សី/ពាក់កណ្តាលស៊ីម៉ង់។ល។)
- **សេវាកម្មមគ្គុទេសក៍ទេសចរណ៍** (មគ្គុទេសក៍ឧទ្យានុរក្ស មគ្គុទេសក៍សហគមន៍ ។ល។)
- **សេវាកម្មដឹកជញ្ជូន** (កង់ កង់អាគុយ ឡានអគ្គីសនី សេវាកម្មរទេះសេះ/គោ សេវាកម្មគោយន្ត និងសេវាកម្មដឹកជញ្ជូនខ្នាតតូចដទៃទៀតដែលមានលក្ខណៈមេត្រីបរិស្ថាន)
- **ការលក់វត្ថុអនុស្សាវរីយ៍** (ទីតាំងលក់វត្ថុអនុស្សាវរីយ៍ធ្វើដោយសហគមន៍ ហាងលក់វត្ថុអនុស្សាវរីយ៍ខ្នាតតូច មជ្ឈមណ្ឌលពិព័រណ៍សិប្បកម្មខ្នាតតូច មជ្ឈមណ្ឌលធ្វើសិប្បកម្មផលិតផលសម្គាល់តំបន់ ឬទីតាំងតូចៗសមស្របសម្រាប់លក់ដូរ ។ល។)
- **ហេដ្ឋារចនាសម្ព័ន្ធ និងសម្ភារទេសចរណ៍ដទៃទៀតដែលត្រូវអនុញ្ញាត** (ទីតាំងមើលទេសភាពធម្មជាតិ ប៉មមើលសត្វព្រៃ កន្លែងចំណតខ្នាតតូច សម្ភារសម្រាប់គ្រប់គ្រងសំណល់ មជ្ឈមណ្ឌលបកស្រាយព័ត៌មាន សម្ភារសម្រាប់ការផ្តល់ដំណឹងជាមុន ទីតាំងដើរព្រៃនិងដើរឡើងភ្នំ បរិក្ខារសុខមាលភាពទេសចរ (រាប់បញ្ចូលទាំងបន្ទប់ទឹកនិងបង្គន់អនាម័យស្តង់ដារបរិស្ថាន) ផ្ទាំងផ្តល់ព័ត៌មាន ស្លាកសញ្ញា មជ្ឈមណ្ឌលព័ត៌មាន សម្ភារសម្រាប់លើកកម្ពស់ការស្រាវជ្រាវនិងការអប់រំ ផ្លូវថ្មើរ ជើង/ជិះកង់ មណ្ឌលសង្គ្រោះបន្ទាន់ ។ល។)

## ២. ប្រភេទសកម្មភាព៖

- ដើរព្រៃ / ដើរឡើងភ្នំ
- ទស្សនា និងឆ្លុះមើលសត្វ / សត្វព្រៃ
- បោះតង់ក្នុងជំរុំតង់ និងបោះតង់ក្នុងជំរុំការ៉ាវ៉ាន់ខ្នាតតូច
- គយគន់ទេសភាព
- ហែលទឹកនៅទឹកជ្រោះ បឹងបួរ/ទន្លេ/ស្ទឹងធម្មជាតិ ។ល។
- ចូលរួមធ្វើវិបស្សនា និងសកម្មភាពក្នុងក្លិបយូហ្គា
- សកម្មភាពពាក់ព័ន្ធនឹងការស្រាវជ្រាវនិងការអប់រំ
- ជិះកង់ ជិះសេះ/រទេះសេះ/រទេះគោ/គោយន្ត

- ជិះឡានអគ្គិសនី / កង់អាគុយ
- ធម្មយាត្រា ឬសកម្មភាពជង្វែសាសនា
- ថតរូបអនុស្សាវរីយ៍
- ជិះទូកកាណូ / ជិះទូក / ជិះទូកកែយាក់
- មុជទឹកក្នុងសមុទ្រ និងមើលផ្កាថ្មនៅបាតសមុទ្រ
- ការលោតទំលាក់ខ្លួនពីទីខ្ពស់
- ការឡើងជញ្ជាំងភ្នំ
- ការលោតឆ័ត្រយោងពីលើយន្តហោះ
- សកម្មភាពកម្សាន្តខ្នាតតូចដទៃទៀត ដែលមានផលប៉ះពាល់អប្បបរមាដល់បរិស្ថានធម្មជាតិធនធានជីវៈចម្រុះ និងវប្បធម៌ក្នុងតំបន់។